ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបលោកនាយកចាត់ការទូទៅក្រុមហ៊ុនកូកាកូឡា កម្ពុជា



នៅរសៀលថ្ងៃទី១២ ខែ សីហា ឆ្នាំ២០១៤ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបជាមួយលោក **Paul Popelier** នាយកចាត់ការទូទៅក្រុមហ៊ុនកូកាកូឡាកម្ពុជា ដែលមានឈ្មោះជាផ្លូវការថា ក្រុមហ៊ុន **Cambodia Beverage Company Ltd** និងសហការី ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។



លោក **Paul Popelier** នាយកចាត់ការទូទៅក្រុមហ៊ុនកូកាកូឡាកម្ពុជា បានថ្លែងអំណរគុណ ចំពោះរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដែលបានជួលទីតាំងឱ្យរោងចក្រកូកាកូឡានៅតំបន់គីឡូម៉ែត្រលេខ០៦ ឬស្សី

កែវ បានដំណើរការប្រកបដោយជោគជ័យនៅកម្ពុជា ។ បច្ចុប្បន្ន ក្រុមហ៊ុនកំពុងពិនិត្យលទ្ធភាពស្វែងរកដីទំនេរ របស់រដ្ឋ រឺ ឯកជន នៅតំបន់ជាយក្រុង ដែលមានទីតាំងសមរម្យ ដើម្បីសាងសង់រោងចក្រថ្មី ដើម្បីអនុវត្តគម្រោងហៅថា វាលស្រែបៃតង (Greenfield Project) ។ លោក នាយកចាត់ការទូទៅ បានបញ្ជាក់ថាៈ ក្រុមហ៊ុន កូកាកូឡា បានមកវិនិយោគនៅកម្ពុជា តាំងពីឆ្នាំ១៩៦៣ បន្ទាប់ពីក្រោយសង្គ្រាម ក្រុមហ៊ុនបានមកវិនិយោគនៅកម្ពុជាម្តងទៀត នៅឆ្នាំ១៩៩៣ ដោយធ្វើអាជីវកម្មកូកាកូឡាច្រកដប និងចែកចាយ ។ នៅឆ្នាំ១៩៩៧ ចាប់ផ្តើមអាជីវកម្ម ច្រកកំប៉ុង និងនៅឆ្នាំ ២០០៨ បានបង្កើនទឹកប្រាក់វិនិយោគ ៣០លានដុល្លា លើខ្សែសង្វាក់ផលិតកម្មថ្មី និងចាប់ពីពេលនោះមក ក្រុមហ៊ុនបានផលិតចេញនូវផលិតផលថ្មីៗជាបន្តបន្ទាប់ ។ លោកនាយកចាត់ការទូទៅ បានបន្ថែមថាៈបច្ចុប្បន្នក្រុមហ៊ុនបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវច្បាប់ទម្លាប់និងលក្ខខ័ណ្ឌតម្រូវនានារបស់កម្ពុជា ដូចជា ច្បាប់វិនិយោគ ច្បាប់ពន្ធ និងច្បាប់ការងារ ជាដើម ។ ជាពិសេស ក្រុមហ៊ុនបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាជាមួយអង្គភាពប្រឆាំងអំពើពុករលួយរបស់កម្ពុជាផងដែរ ។ ជាមួយគ្នានេះ ក្រុមហ៊ុនក៏បានលើកឡើងនូវបញ្ហាប្រឈមមួយចំនួន ដូចជា ការទាក់ទង និងការចុះបញ្ជីផលិតផល ការប្រកួតប្រជែងមិនស្មោះត្រង់ និងផលិតផលខ្លះមិនអនុលោមតាមស្តង់ដា ហើយអាចដាក់លក់លើទីផ្សារបានដូចគ្នា ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះភាពរីកចម្រើនរបស់ក្រុមហ៊ុន ដែលបានជួយរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច ទីផ្សារការងារ និងការចូលរួមទទួលខុសត្រូវសង្គមនៅកម្ពុជា ។

ទាក់ទង និងការស្វែងរកទីតាំង ដើម្បីសាងសង់រោងចក្រថ្មី ឯកឧត្តម បានផ្តល់អនុសាសន៍ សម្រាប់ជាជម្រើស លើទីតាំងនៃតំបន់មួយចំនួន ដូចជាៈតំបន់ទំនប់កប់ស្រូវ តំបន់ផ្លូវជាតិលេខ៤ ជិតតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ និងតំបន់ផ្លូវជាតិលេខ៥ ជាដើម ។ ចំពោះបញ្ហាប្រឈម ដែលក្រុមហ៊ុនលើកឡើង ឯកឧត្តម ទេសរដ្ឋមន្ត្រី បានពន្យល់ថាៈការងារចុះបញ្ជីផលិតផល បច្ចុប្បន្នត្រូវបានចុះបញ្ជីនៅវិទ្យាស្ថានស្តង់ដារវិញ ដែលកាលពីមុន ត្រូវចុះនៅអគ្គនាយកដ្ឋាន សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ។ ឯកឧត្តម បានបញ្ជាក់ថាៈ ទោះបីប្តូរអង្គភាព រឺ មនុស្សទទួលខុសត្រូវក៏ដោយ តែច្បាប់មិនបានផ្លាស់ប្តូរទេ ។ ចំពោះការប្រកួតប្រជែងមិនស្មោះត្រង់ និងផលិតផលមិនអនុលោមតាមស្តង់ដា និងបទដ្ឋានបច្ចេក

ទេសត្រឹមត្រូវ ក្រសួងកំពុងតែចាត់ការ តាមវិធានការចុះធ្វើអធិការកិច្ចតាមមូលដ្ឋានផលិតផល ក្នុងរោងចក្រជាបន្តបន្ទាប់ ។ ទាក់ទងនិង ការចូលរួមទទួលខុសត្រូវសង្គមរបស់ក្រុមហ៊ុន ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានថ្លែងអំណរគុណចំពោះក្រុមហ៊ុនកូកាកូឡាកម្ពុជា ដែលនឹងស្វាគមន៍ដោយរីករាយចំពោះវគ្គបណ្តុះបណ្តាលនានា ដែលជាកម្មវិធីរបស់ក្រសួង

ដោយក្រុមហ៊ុនមានផ្តល់ ទីតាំង អាហារ ភេសជ្ជៈ និងទឹកបរិសុទ្ធ ជាដើម ដល់សិក្ខាកាមក្នុងវគ្គសិក្សានីមួយៗ តាមកម្មវិធីរបស់ក្រសួង ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបញ្ជាក់ថា៖ ក្រសួងបានមានផែនការ លើការងារបណ្តុះបណ្តាលការលើកកំពស់ផលិតភាព និងស្តង់ដារ ផលិតផល ដល់សហគ្រិន និងម្ចាស់រោងចក្រ និងកម្មវិធីសិក្សាស្រាវជ្រាវ អ្នកវិទ្យាសាស្ត្រវ័យក្មេងកម្ពុជា រឺកម្មវិធីប្រកួត ប្រជែង អនុវត្តផលិតកម្មល្អ និងអនាម័យល្អ និងការអនុវត្តគោលការណ៍ ស៥ (សម្រិតសម្រាំង សណ្តាប់ធ្នាប់ សម្អាត ស្តង់ដារ និងស្ថិតស្ថេរ) ជាដើម ។